# លទ្ធផលស្ដីពីការវាយតម្លៃអំពី ការត្រៀមលក្ខណៈនៃប្រព័ន្ធគាំពារសង្គម ក្នុងការឆ្លើយតបនឹងគ្រោះអាសន្ននៅកម្ពុជា

សង្ខេបគោលនយោបាយលេខ ១៥



រៀបចំដោយក្រុមប្រឹក្សាជាតិគាំពារសង្គម
ខែធ្នូ ឆ្នាំ២០២៥

# ១ សេចក្តីផ្តើម

សង្ខេបគោលនយោបាយនេះបង្ហាញអំពីលទ្ធផលសំខាន់ៗស្តីពីការវាយតម្លៃអំពីការត្រៀមលក្ខណៈនៃប្រព័ន្ធគាំពារសង្គមក្នុងការឆ្លើយតបនឹងគ្រោះអាសន្ននៅកម្ពុជា ដែលត្រូវបានរៀបចំឡើងក្រោមកិច្ចសហការរវាងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គមកម្ពុជា និងធនាគារពិភពលោក។ ការវាយតម្លៃនេះមានគោលបំណងពិនិត្យ និងវាស់វែងកម្រិតត្រៀមខ្លួនជាស្រេចក្នុងការអនុវត្តប្រព័ន្ធគាំពារសង្គមដែលមានភាពបត់បែន (Adaptive social protection system) នៅកម្ពុជា ដោយធៀបនឹងឧត្តមានុវត្តន៍នានា ដើម្បីផ្តល់ជាចំណេះដឹងក្នុងការបង្កើនសមត្ថភាព និងជាធាតុចូលសម្រាប់រៀបចំគោលនយោបាយក្នុងគោលបំណងបន្តពង្រឹងភាពបត់បែន និងពង្រីកវិសាលភាពនៃប្រព័ន្ធគាំពារសង្គមសម្រាប់ឆ្លើយតបនឹងគ្រោះអាសន្ននានា ជាពិសេសតាមរយៈការរៀបចំនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់។

ការវាយតម្លៃនេះ ត្រូវបានអនុវត្តចាប់ពីខែវិច្ឆិកា ឆ្នាំ២០២២ ដល់ខែមេសា ឆ្នាំ២០២៣ ហើយត្រូវបានធ្វើបច្ចុប្បន្នកម្មព័ត៌មាន និងទិន្នន័យចាប់ពីខែមិថុនា ដល់ ខែសីហា ឆ្នាំ២០២៤ ដើម្បីឆ្លុះបញ្ចាំងអំពីវឌ្ឍនភាព និងកំណែទម្រង់ជាបន្តបន្ទាប់នៃប្រព័ន្ធគាំពារសង្គមកម្ពុជា ដោយផ្តោតលើបណ្តុំជាមូលដ្ឋានសំខាន់ៗចំនួន ៤ រួមមាន៖ ការរៀបចំយន្តការកម្មវិធី និងប្រព័ន្ធបើកផ្តល់, ប្រព័ន្ធទិន្នន័យ និងព័ត៌មាន, យន្តការហិរញ្ញប្បទាន, និងយន្តការស្ថាប័ន និងភាពជាដៃគូ។ បណ្តុំមូលដ្ឋាននីមួយៗត្រូវបានវាយតម្លៃដោយប្រើប្រាស់កម្រងសំណួរជាក់លាក់ និងត្រូវបានចាត់ចំណាត់ថ្នាក់ពីចន្លោះពិន្ទុ ១ រហូតដល់ ៥ ដោយផ្អែកលើវឌ្ឍនភាពការងារ៖

(១) មិនទាន់មានវឌ្ឍនភាព ✿

(២) ទើបចាប់ផ្តើមមានវឌ្ឍនភាព ✿✿

(៣) កំពុងមានវឌ្ឍនភាព ✿✿✿

(៤) មានវឌ្ឍនភាពខ្ពស់ ✿✿✿✿

(៥) អភិវឌ្ឍន៍ ✿✿✿✿✿

ការវាយតម្លៃនេះ បានពិនិត្យ និងវិភាគបន្ថែមលើព័ត៌មាន និងទិន្នន័យនៃរបាយការណ៍នានារបស់រាជរដ្ឋាភិបាល និងអង្គការអន្តរជាតិ, ការពិនិត្យលើឯកសារពាក់ព័ន្ធនានា, និងការសម្ភាសន៍ជាមួយភាគីពាក់ព័ន្ធ។

# ២

## វឌ្ឍនភាពនៃការអនុវត្តកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន




ក្នុងរយៈពេលប្រមាណ ៥ ឆ្នាំចុងក្រោយនេះ, រាជរដ្ឋាភិបាលបានធ្វើការវិនិយោគដ៏ច្រើនសន្ធឹក-សន្ធាប់ដើម្បីពង្រឹង និងពង្រីកប្រព័ន្ធគាំពារសង្គម ដោយសម្រេចបានលទ្ធផលគួរឱ្យកត់សម្គាល់ដែលនេះបានបង្កើតជាមូលដ្ឋានដ៏រឹងមាំសម្រាប់ដាក់ចេញនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ក្នុងអំឡុងវិបត្តិនានា ដូចជាវិបត្តិពីជំងឺកូវីដ-១៩, សម្ពាធអតិផរណាខ្ពស់, និងគ្រោះទឹកជំនន់ធ្ងន់ធ្ងរ ក្នុងគោលបំណងជួយរក្សាលំនឹងជីវភាពរបស់ប្រជាពលរដ្ឋ ជាពិសេសពលរដ្ឋក្រីក្រ និងងាយរងគ្រោះ។

ផ្អែកតាមបទពិសោធវិជ្ជមានពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ទាំងនេះ ជាពិសេសកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដែលបានអនុវត្តចាប់ពី ខែមិថុនា ឆ្នាំ២០២០ ដល់ ខែមីនា ឆ្នាំ២០២៤ គ្របដណ្តប់គ្រួសារមានបណ្ណសមធម៌**ប្រមាណ ៧០០ ០០០ គ្រួសារ** និងចំណាយថវិការដ្ឋសរុបចំនួនប្រមាណ **៥ ៤៣៨ ប៊ីលានរៀល ស្មើនឹងប្រមាណ ១ ៣៦០ លានដុល្លារអាម៉េរិក**, រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តក្នុងការធ្វើស្ថាប័នូបនីយកម្មប្រព័ន្ធគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ដោយកំណត់ជាកម្មវិធីគោលនយោបាយអាទិភាព១ ក្នុងចំណោមកម្មវិធីគោលនយោបាយអាទិភាពទាំង ៦ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។ ជាលទ្ធផល គោលការណ៍ណែនាំស្តីពីក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ កាលពីខែធ្នូ ឆ្នាំ២០២៣ កន្លងទៅ ក្នុងគោលបំណងជំរុញការប្រើប្រាស់ប្រព័ន្ធគាំពារសង្គមក្នុងការផ្តល់ការគាំពារដែលមានលក្ខណៈជាប្រព័ន្ធ, អាចព្យាករទុកមុន, ទាន់ពេល, និងមានប្រសិទ្ធភាពខ្ពស់ជូនប្រជាពលរដ្ឋ ពិសេសប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះ។

តាមរយៈនេះ ក្នុងឆ្នាំ២០២៤-២០២៥ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម បានសហការ និងសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធដើម្បីអនុវត្តសកម្មភាពអាទិភាពសំខាន់ៗនៃគោលការណ៍ណែនាំឆ្លើយតបនឹងគ្រោះអាសន្ន រួមមានៈការវិភាគហានិភ័យ និងធ្វើម៉ូដែលចំណាយ, ការវាយតម្លៃ, ទំនាក់ទំនង, ការរៀបចំផែនការប្រតិបត្តិ និងការបង្កើតក្របខណ្ឌដាក់ចេញអន្តរាគមន៍សម្រាប់ការឆ្លើយតបនឹងគ្រោះទឹកជំនន់។

បន្ថែមលើនេះ ក្នុងអំឡុងវិបត្តិពីជម្លោះព្រំដែនកម្ពុជា-ថៃ ដែលបណ្តាលឱ្យមានកម្មវិបាកអវិជ្ជមានមកលើជីវភាពរបស់ប្រជាពលរដ្ឋ រាជរដ្ឋាភិបាលបានសម្រេចកែសម្រួលយន្តការអនុវត្ត និងលើកលែងលក្ខខណ្ឌអនុវត្តកម្មវិធីមួយចំនួន ដើម្បីធានាឱ្យបាននូវការបន្តទទួលបានអត្ថប្រយោជន៍ពីកម្មវិធីជាតិជំនួយសង្គមក្នុងអំឡុងនៃវិបត្តិ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបាន និងកំពុងគិតគូររៀបចំកម្មវិធីអន្តរាគមន៍ពិសេសសម្រាប់គ្រួសារដែលត្រូវបានជម្លៀសចេញពីភូមិសាស្ត្រជម្លោះព្រំដែន ព្រមទាំងពលករ និងកម្មករនិយោជិតដែលរងកម្មវិបាកពីវិបត្តិនេះផងដែរ។

## ៣ លទ្ធផលគន្លឹះនៃការវាយតម្លៃ

ផ្អែកតាមការវិវត្តយ៉ាងឆាប់រហ័សនៃប្រព័ន្ធគាំពារសង្គម រួមទាំងការដាក់ចេញនូវគោលនយោបាយ និងកម្មវិធី និងរបបថ្មីៗនាពេលកន្លងមក ពិសេសការប្រកាសដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្ដីពីក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន, លទ្ធផលនៃការវាយតម្លៃបានបង្ហាញថា ការត្រៀមលក្ខណៈនៃប្រព័ន្ធគាំពារសង្គមក្នុងការឆ្លើយតបនឹងគ្រោះអាសន្ននៅកម្ពុជា សម្រេចបានវឌ្ឍនភាពល្អប្រសើរ ដោយទទួលបានពិន្ទុជាមធ្យម ៣,៥ ពិន្ទុ លើ ៥ ទៅតាមបណ្ដុំមូលដ្ឋាននានា ដូចមានក្នុងរូបភាពខាងក្រោម។




លទ្ធផលគន្លឹះសង្ខេបស្ដីពីកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ដោយបែងចែកទៅតាមបណ្ដុំមូលដ្ឋាននីមួយៗមានដូចខាងក្រោម៖

### ក. ការរៀបចំយន្តការកម្មវិធី និងប្រព័ន្ធបើកផ្ដល់

#### ការរៀបចំយន្តការកម្មវិធី៖

- កម្មវិធីជំនួយសង្គមសំខាន់ៗ ត្រូវបានដាក់ចេញដើម្បីឆ្លើយតបនឹងគ្រោះអាសន្នពីវិបត្តិនៃជំងឺកូវីដ-១៩, សម្ពាធអតិផរណាខ្ពស់, គ្រោះទឹកជំនន់ធ្ងន់ធ្ងរ, និងជម្លោះព្រំដែន ដោយផ្អែកលើធនធានសមត្ថភាព, ប្រព័ន្ធព័ត៌មាន, យន្តការបើកផ្ដល់សាច់ប្រាក់, និងចំណេះដឹងទទួលបានពីការអនុវត្តកម្មវិធីជំនួយសង្គមប្រក្រតីនានា។
- បន្ទាប់ពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវបានបិទបញ្ចប់ទាំងស្រុង, កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ត្រូវបានដាក់ឱ្យអនុវត្តសម្រាប់គ្រួសារមានបណ្ណសមធម៌ ដែលជាកម្មវិធីមានលក្ខណៈសមាហរណ សំដៅកាត់បន្ថយភាពក្រីក្រ និងហានិភ័យតាមវដ្ដជីវិត។

- គ្រួសារងាយរងហានិភ័យ ឬក្បែរក្រ ដែលជាក្រុមគោលដៅថ្មីនៃប្រព័ន្ធគាំពារសង្គម ត្រូវបានកំណត់អត្តសញ្ញាណ និងទទួលបានអត្ថប្រយោជន៍ពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់បន្ទាន់នានាក្នុងអំឡុងមានគ្រោះអាសន្ន ហើយបន្ទាប់ពីកម្មវិធីទាំងនេះត្រូវបានបិទបញ្ចប់, ក្រុមគោលដៅនេះបានចាប់ផ្តើមទទួលបានអត្ថប្រយោជន៍ពីកម្មវិធីជំនួយសង្គមប្រក្រតីមួយចំនួន ដូចជាមូលនិធិសមធម៌សុខាភិបាល និងកម្មវិធីជាតិជំនួយសង្គមផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស សម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ។

### ប្រព័ន្ធបើកផ្តល់៖

- យុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយគ្រប់ជ្រុងជ្រោយត្រូវបានប្រើប្រាស់ដើម្បីជំរុញការអនុវត្តកម្មវិធីក្នុងអំឡុង និងក្រោយពេលគ្រោះអាសន្ន បើទោះបីជាការអនុវត្តនៅមានលក្ខណៈមួយពេល (Ad hoc) នៅឡើយ។
- ការចុះឈ្មោះចូលកម្មវិធីឧបត្ថម្ភសាច់ប្រាក់ឆ្លើយតបនឹងគ្រោះអាសន្ននានា ត្រូវបានធ្វើឡើងដោយស្វ័យប្រវត្តិសម្រាប់គ្រួសារក្រីក្រថ្មី និងគ្រួសារងាយរងហានិភ័យ តាមរយៈយន្តការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ដើម្បីធានាឱកាសក្នុងការទទួលបានប្រាក់ឧបត្ថម្ភ។
- ទិដ្ឋភាពងាយរងគ្រោះជាក់លាក់ត្រូវបានដាក់បញ្ចូលក្នុងយន្តការកំណត់អត្តសញ្ញាណគ្រួសារគោលដៅ ពិសេសការកំណត់អត្តសញ្ញាណគ្រួសារងាយរងហានិភ័យ ដើម្បីធានាឱ្យបាននូវបរិយាបន្នយេនឌ័រ និងក្រុមជនងាយរងគ្រោះផ្សេងៗក្នុងប្រព័ន្ធគាំពារសង្គម។
- ឧបករណ៍សម្រាប់វាយតម្លៃតម្រូវការគ្រួសារក្រោយពេលគ្រោះអាសន្ន ត្រូវបានប្រើប្រាស់ ប៉ុន្តែមិនមានយន្តការដើម្បីតភ្ជាប់ឧបករណ៍នេះទៅនឹងកម្មវិធីជំនួយសង្គមសម្រាប់ការឆ្លើយតបនឹងគ្រោះអាសន្ន។
- ការដាក់ពាក្យបណ្តឹងតវ៉ា និងការតាមដានការឆ្លើយតបដោយអ្នកទទួលផល អាចត្រូវបានធ្វើឡើងតាមរយៈវិធីសាស្ត្រច្រើន។

### ប្រព័ន្ធបើកផ្តល់សាច់ប្រាក់៖

- យន្តការបើកផ្តល់សាច់ប្រាក់នៃកម្មវិធីជំនួយសង្គមប្រក្រតី ពឹងផ្អែកលើសេវាកម្មរបស់ស្ថាប័នបើកផ្តល់សាច់ប្រាក់តែមួយជម្រើស។
- គណនីសន្សំធនាគារត្រូវបានផ្តល់ជូនគ្រួសារទទួលផលនានា រួមទាំងសម្រាប់កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដើម្បីដកសាច់ប្រាក់ ដែលនេះត្រូវបានពង្រីកវិសាលភាពយ៉ាងឆាប់រហ័សសម្រាប់ការអនុវត្តកម្មវិធីឆ្លើយតបនឹងគ្រោះអាសន្ននានា។ យ៉ាងណាមិញ គណនីធនាគារនេះ មិនមែនជាគណនីពេញលេញនោះទេ ដែលនេះធ្វើឱ្យការរួមចំណែកក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ នៅមានកម្រិត។

## ខ. ប្រព័ន្ធទិន្នន័យ និងព័ត៌មាន

### ការវាយតម្លៃភាពងាយរងគ្រោះ និងហានិភ័យ

- ប្រព័ន្ធប្រកាសដំណឹងឱ្យដឹងជាមុន (Early warning system) សម្រាប់គ្រោះទឹកជំនន់ បាន និងកំពុងដំណើរការ និងមានសមត្ថភាពក្នុងការតាមដានស្ថានភាពទឹកជំនន់។ យ៉ាងណាមិញ ប្រព័ន្ធនេះមិនទាន់មានដំណើរការនៅឡើយសម្រាប់ហានិភ័យសំខាន់ផ្សេងទៀត ដូចជាគ្រោះរាំងស្ងួត ដែលត្រូវពិនិត្យ និងសិក្សាបន្ថែម ដើម្បីគាំទ្រដល់ការអនុវត្តកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន។

- សមត្ថភាពតាមដាន និងការជូនដំណឹងជាមុន អាចត្រូវបានពង្រឹងបន្ថែមទៀតលើផ្នែកដូចជា ពេលវេលាដឹងមុនសម្រាប់ការជូនដំណឹង និងការព្យាករណ៍, ចំនួនបុគ្គលិក, បច្ចេកវិទ្យា និងការថែទាំ Software, ពិធីសារចែករំលែកទិន្នន័យ, ប្រព័ន្ធគ្រប់គ្រងទិន្នន័យ, និងជំនាញព្យាករណ៍សម្រាប់រយៈពេលវែង។
- ការវាយតម្លៃពីភាពងាយរងគ្រោះ និងហានិភ័យ ត្រូវបានធ្វើឡើងដើម្បីកំណត់កម្មវិបាកពីគ្រោះអាសន្នសំខាន់ៗលើក្រុមប្រជាជននានា ប៉ុន្តែការប្រើប្រាស់លទ្ធផលនៃការវាយតម្លៃសម្រាប់កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ននៅមានកម្រិតនៅឡើយ។

### ការចុះបញ្ជីសង្គម៖

- តាមរយៈយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ប្រមាណ ៣០% នៃគ្រួសារសរុបនៅកម្ពុជា ត្រូវបានកំណត់អត្តសញ្ញាណជាគ្រួសារក្រីក្រ ឬគ្រួសារងាយរងហានិភ័យ ជាមួយទិន្នន័យមានបច្ចុប្បន្នភាព ហើយយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ បានវិវត្តទៅជាយន្តការតាមការស្នើសុំ ដើម្បីកំណត់ និងចុះឈ្មោះគ្រួសារក្រីក្រ និងងាយរងគ្រោះ។
- ទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ មានលក្ខណៈគ្រប់គ្រាន់សម្រាប់ឆ្លើយតបនូវរាល់គ្រោះអាសន្ន នៅពេលចាំបាច់ បើទោះបីជាការគ្របដណ្តប់តំបន់ប្រជុំជន ដែលងាយរងគ្រោះអាសន្ននៅមានកម្រិតទាបជាងនៅតំបន់ជនបទ។
- ការធ្វើសុខដុមនីយកម្មទិន្នន័យគាំពារសង្គម ដើម្បីបង្កើតប្រព័ន្ធចុះបញ្ជីសង្គម ( Social Protection Registry ) បាន និងកំពុងអនុវត្ត ដោយរួមបញ្ចូលទិន្នន័យពីមូលដ្ឋានទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ, បេឡាជាតិសន្តិសុខសង្គម, និងប្រភពផ្សេងៗទៀត តាមរយៈស្រទាប់អន្តរប្រតិបត្តិការ CamDX និងធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណជាមួយអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ។

## គ. ហិរញ្ញប្បទាន

- ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវបានអនុម័តដោយរដ្ឋសភាជាតិកម្ពុជា នៅឆ្នាំ ២០១៥ ដោយកំណត់ឱ្យរាជរដ្ឋាភិបាល **"ត្រូវមានថវិកាត្រៀមបម្រុង និងធនធានសមស្រប ដើម្បីធានាសម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយ"** រួមទាំងការត្រៀមលក្ខណៈ, ការឆ្លើយតប, និងការស្តារឡើងវិញ។
- យុទ្ធសាស្ត្រហិរញ្ញប្បទានសម្រាប់ហានិភ័យគ្រោះមហន្តរាយ ២០២៤-២០២៨ ត្រូវបានអនុម័ត ក្នុងខែមិថុនា ឆ្នាំ២០២៤ ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវភាពធន់ផ្នែកហិរញ្ញវត្ថុនៅកម្ពុជាឆ្លើយតបនឹងហានិភ័យគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ។ យុទ្ធសាស្ត្រនេះបានបង្ហាញពីឧបករណ៍ហិរញ្ញប្បទានសម្រាប់ហានិភ័យគ្រោះមហន្តរាយ និងផែនការរយៈពេលមធ្យមទៅតាមវិស័យនានា ព្រមទាំងកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន។
- ការសម្របសម្រួលរវាងក្រសួង-ស្ថាប័ន នៅមានតម្រូវការបន្ថែមទៀតសម្រាប់ បង្កើនការយល់ដឹងអំពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ, ផ្តល់អាទិភាពដល់ការវិនិយោគលើយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យ, បែងចែកធនធានចាំបាច់ដើម្បីគ្រប់គ្រងគ្រោះមហន្តរាយ, និងលើកកម្ពស់ឧបករណ៍ហិរញ្ញវត្ថុសម្រាប់ហានិភ័យគ្រោះមហន្តរាយ ដើម្បីធានាឱ្យមានលទ្ធភាពទទួលបានមូលនិធិសម្រាប់ការឆ្លើយតបបន្ទាន់នឹងគ្រោះមហន្តរាយ និងការស្តារឡើងវិញ។
- ថវិកាត្រៀមបម្រុងទូទៅ ត្រូវបានប្រើប្រាស់ឆ្លើយតបនឹងគ្រោះអាសន្នដែលមិនបានរំពឹងទុក ប៉ុន្តែថវិកានេះមិនបានត្រៀមសម្រាប់ការចំណាយក្រោយពេលគ្រោះអាសន្នតែមួយមុខគត់នោះទេ ហើយការផ្តល់ហិរញ្ញប្បទានក៏ជាយន្តការមួយពេលៗ សម្រាប់កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន។ ការអនុវត្តយុទ្ធសាស្ត្រហិរញ្ញប្បទានសម្រាប់ហានិភ័យគ្រោះមហន្តរាយ នឹងធ្វើឱ្យប្រសើរឡើងនូវការអនុវត្តកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន។

## ឃ. យន្តការស្ថាប័ន

- គោលការណ៍ណែនាំស្តីពីក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ត្រូវបានអនុម័តដាក់ឱ្យប្រើប្រាស់។ គោលការណ៍ណែនាំនេះផ្តល់នូវការបំពេញឱ្យគ្នារវាងប្រព័ន្ធគាំពារសង្គម និងការគ្រប់គ្រងគ្រោះមហន្តរាយ និងផ្សារភ្ជាប់ជាមួយក្របខណ្ឌគតិយុត្តផ្សេងៗ។ គោលការណ៍ណែនាំនេះអាចត្រូវបានពង្រឹងបន្ថែមទៀត តាមរយៈការរៀបចំគតិយុត្ត និងការធានាផ្នែកហិរញ្ញវត្ថុសម្រាប់គាំទ្រកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន និងការគ្រប់គ្រងគ្រោះមហន្តរាយ។
- ផែនការត្រៀមបម្រុងសម្រាប់ឆ្លើយតបនឹងគ្រោះមហន្តរាយចម្បងៗ ត្រូវបានរៀបចំឡើង ប៉ុន្តែសមត្ថភាព និងធនធានតាមស្ថាប័នសម្រាប់ធានាការអនុវត្តឱ្យបានពេញលេញនៅមានកម្រិតនៅឡើយ។
- ការតភ្ជាប់ និងការសម្របសម្រួលរវាងស្ថាប័នពាក់ព័ន្ធក្នុងប្រព័ន្ធគាំពារសង្គម និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ កំពុងត្រូវបានធ្វើឱ្យប្រសើរឡើង។ ក្នុងឆ្នាំ២០២១, អនុក្រឹត្យលេខ ១៤៣ អនក្រ.បក បានដាក់បញ្ចូលតំណាងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ជាសមាជិកនៃគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម។



៤

# អនុសាសន៍គោលនយោបាយ

## ក. ការរៀបចំយន្តការកម្មវិធី និងប្រព័ន្ធបើកផ្តល់

- បន្តពង្រីកការគ្របដណ្តប់ប្រជាជន និងពង្រឹងភាពគ្រប់គ្រាន់នៃកម្មវិធីជំនួយសង្គមប្រក្រតី ដើម្បីបង្កើនភាពធន់របស់គ្រួសារក្នុងការឆ្លើយតបនឹងគ្រោះអាសន្ន
- បញ្ជូលសមាសធាតុស្តីពីការឆ្លើយតបនឹងគ្រោះអាសន្នទៅក្នុងសៀវភៅស្តង់ដាប្រតិបត្តិ នៃកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមប្រក្រតីនានា ក្នុងប្រព័ន្ធគាំពារសង្គម ដើម្បីធានាឱ្យបានការត្រៀមលក្ខណៈឆ្លើយតបនឹងគ្រោះអាសន្នរួមមាន៖ ការពង្រីកវិសាលភាពកម្មវិធី, ការពង្រឹងទំនាក់ទំនង, ការចុះឈ្មោះតាមរយៈវិធីសាស្ត្រផ្សេងៗ, និងការបើកផ្តល់អត្ថប្រយោជន៍ដោយងាយស្រួលនៅក្នុងតំបន់ដាច់ស្រយាលដែលរងផលប៉ះពាល់ពីគ្រោះមហន្តរាយ
- បង្កើតក្របខណ្ឌដាក់ចេញអន្តរាគមន៍ និងនីតិវិធី និងដំណើរការដាក់ចេញអន្តរាគមន៍សម្រាប់ការឆ្លើយតបនឹងគ្រោះអាសន្នចម្បងៗ ដែលកំណត់នូវកម្មវិធី និងយន្តការដាក់លាក់ សម្រាប់អនុវត្ត, ក្រុមអ្នកទទួលផល, កម្រិតអត្ថប្រយោជន៍, រយៈពេលឆ្លើយតប, ទិន្នន័យដាក់ចេញអន្តរាគមន៍ (Triggers), និងតួនាទីរបស់ស្ថាប័ន
- ពង្រឹងឧបករណ៍វាយតម្លៃស្ថានភាពគ្រួសារក្រោយពេលគ្រោះអាសន្ន ដើម្បីផ្តល់ធាតុចូលសម្រាប់រៀបចំ និងដំណើរការកម្មវិធីជំនួយសង្គមនៅពេលមានគ្រោះអាសន្ន
- បង្កើនជម្រើសស្ថាប័នបើកផ្តល់សាច់ប្រាក់ និងធ្វើការបើកផ្តល់ទៅកាន់គណនីសន្សំពេញលេញ ដើម្បីជំរុញបរិយាបន្នហិរញ្ញវត្ថុរបស់គ្រួសារ។

## ខ. ប្រព័ន្ធទិន្នន័យ និងព័ត៌មាន

- បន្តពង្រឹងសមត្ថភាពរបស់ក្រសួង-ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដើម្បីតាមដាន និងជូនដំណឹងអំពីការកើតឡើងនៃព្រឹត្តិការណ៍គ្រោះមហន្តរាយ និងដើម្បីចាត់វិធានការ
- បន្តអភិវឌ្ឍឋាមវន្តនៃការចុះបញ្ជីគាំពារសង្គម និងអន្តរប្រតិបត្តិការរវាងមូលដ្ឋានទិន្នន័យ រួមមានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ, បេឡាជាតិសន្តិសុខសង្គម, និងប្រព័ន្ធអេឡិចត្រូនិចកត់ត្រានិងគ្រប់គ្រងទិន្នន័យអ្នកជំងឺ ដោយផ្ទៀងផ្ទាត់ទិន្នន័យជាមួយទិន្នន័យអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងធ្វើសុខដុមនីយកម្មការចុះបញ្ជី និងការគ្រប់គ្រងទិន្នន័យក្នុងប្រព័ន្ធគាំពារសង្គម
- ពង្រីកវិសាលភាពគ្របដណ្តប់នៃយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ពិសេសនៅតាមតំបន់ទីប្រជុំជនដែលងាយរងហានិភ័យ
- បង្កើនសមត្ថភាពឆ្លើយតបនឹងគ្រោះអាសន្នរបស់យន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដោយផ្តោតសំខាន់លើយុទ្ធសាស្ត្រទំនាក់ទំនង, ការចុះឈ្មោះតាមវិធីសាស្ត្រច្រើន, និងយន្តការផ្ទៀងផ្ទាត់ព័ត៌មានបន្ថែមផ្សេងៗ។

## គ. យន្តការហិរញ្ញប្បទាន

- អនុវត្តអភិក្រមជាយុទ្ធសាស្ត្រនៃហិរញ្ញប្បទានឆ្លើយតបនឹងគ្រោះមហន្តរាយ សម្រាប់ប្រព័ន្ធគាំពារសង្គម ដោយដាក់បញ្ចូលហិរញ្ញប្បទានសម្រាប់គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ ទៅក្នុងគោលនយោបាយ និងគតិយុត្តសំខាន់ៗ, ធ្វើឱ្យប្រសើរឡើងនូវការប្រមូលទិន្នន័យ និងព័ត៌មាន, ប្រើឧបករណ៍វិភាគ ឬម៉ូឌែលផ្សេងៗក្នុងការវាយតម្លៃកម្មវិបាកគ្រោះមហន្តរាយសម្រាប់ជាធាតុចូលក្នុងការធ្វើផែនការសេដ្ឋកិច្ច និងការគ្រោងថវិកា, កាត់បន្ថយគម្លាតហិរញ្ញប្បទានសម្រាប់ឆ្លើយតបនឹងគ្រោះមហន្តរាយនានា, និងអនុវត្តក្របខណ្ឌស្រទាប់ហានិភ័យ (Risk layering framework) ដើម្បីកំណត់ឧបករណ៍ហិរញ្ញប្បទានហានិភ័យរួម មានភាពចម្រុះ និងមានប្រសិទ្ធភាពថវិកា
- បង្កើត និងអនុវត្តយន្តការហិរញ្ញប្បទានឆ្លើយតបនឹងគ្រោះមហន្តរាយ សម្រាប់កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន។

## ឃ. យន្តការស្ថាប័ន

- បន្តគាំទ្រការអនុវត្តកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ដោយរៀបចំគតិយុត្ត និងការធានាផ្នែកហិរញ្ញវត្ថុ
- រៀបចំបញ្ចប់ផែនការប្រតិបត្តិនៃគោលការណ៍ណែនាំស្តីពីក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន
- ពង្រឹងយន្តការផ្សារភ្ជាប់ និងសម្របសម្រួលរវាងប្រព័ន្ធគាំពារសង្គម និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ តាមរយៈការធ្វើស្ថាប័នូបនីយកម្មនូវការចែករំលែកទិន្នន័យ និងព័ត៌មាន និងការរៀបចំយន្តការសម្របសម្រួលរវាងក្រសួង-ស្ថាប័ន និងទីភ្នាក់ងារមិនមែនរដ្ឋាភិបាលនានា។



៩

# សេចក្តីសន្និដ្ឋាន

រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តខ្ពស់ក្នុងការបន្តពង្រឹងប្រព័ន្ធគាំពារសង្គម ព្រមទាំងការឆ្លើយតបនឹងគ្រោះអាសន្នតាមរយៈប្រព័ន្ធគាំពារសង្គម ដូចមានភស្តុតាងតាមរយៈការដាក់ឱ្យអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ក្នុងអំឡុងមានគ្រោះអាសន្ននានាដែលមានកម្មវិបាកវិជ្ជមានលើជីវភាពរបស់ប្រជាពលរដ្ឋ។ នៅដំណាច់ឆ្នាំ២០២៣ កន្លងទៅ, រាជរដ្ឋាភិបាលបានអនុម័តគោលការណ៍ណែនាំស្តីពីក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ក្នុងគោលបំណងធ្វើស្ថាប័នូបនីយកម្មការឆ្លើយតបនឹងគ្រោះអាសន្នតាមរយៈការប្រើប្រាស់ប្រព័ន្ធគាំពារសង្គមក្នុងការផ្តល់ការគាំពារដែលមានលក្ខណៈជាប្រព័ន្ធ, អាចព្យាករទុកមុន, ទាន់ពេល, និងមានប្រសិទ្ធភាព។ តាមរយៈការវិវត្តជាវិជ្ជមានទាំងនេះ, ការវាយតម្លៃបានបង្ហាញថាការត្រៀមលក្ខណៈនៃប្រព័ន្ធគាំពារសង្គមក្នុងការឆ្លើយតបនឹងគ្រោះអាសន្ននៅកម្ពុជា សម្រេចបានវឌ្ឍនភាព ល្អប្រសើរទៅតាមបណ្តុំមូលដ្ឋាននានា។ យ៉ាងណាមិញ កិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត គួរត្រូវបានអនុវត្ត ដូចមានរំលេចក្នុងអនុសាសន៍គោលនយោបាយខាងលើនេះ។

គាំពារ
សង្គម
កម្ពុជា
SOCIAL PROTECTION IN CAMBODIA